PTI0083

**សម្ភាសន៍ជាមួយឈ្មោះ កែវ រឿន ភេទប្រុស អាយុ៩៨ឆ្នាំ**

**រស់នៅភូមិចំការជ្រៃខាងត្បូង ឃុំអន្លុងរាប ស្រុកវាលវែង ខេត្តពោធិ៍សាត់**

**មុខងារសម័យខ្មែរក្រហមៈ មេក្រុមកងទ័ពខ្មែរក្រហម**

**មុខងារបច្ចុប្បន្នៈ ធ្វើចំការ**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**សម្ភាសន៍ថ្ងៃទី២៣ ខែ ឧសភា ឆ្នាំ២០១១**

**សរុបទំព័រៈ ២៦**

**០១:១៧:២៦**

ដានីៈ ពូជីបូនខ្ញុំចង់ស្គាល់ឈ្មោះពូពេញ តើពូឈ្មោះអីដែរ?

រឿនៈ ឈ្មោះ កែវ រឿន។

ដានីៈ អាយុប៉ុន្មានហើយពូ?

រឿនៈ អាយុ៩៨ឆ្នាំ។

ដានីៈ ពូរស់នៅក្នុងភូមិអីដែរសព្វថ្ងៃនេះ?

រឿនៈ នៅភូមិចំការជ្រៃខាងត្បូង ឃុំអន្លុងរាប ស្រុកវាលវែង។

ដានីៈ ខេត្ត?

រឿនៈ ខេត្តពោធិ៍សាត់។

ដានីៈ ប្រពន្ធរបស់លោកពូគាត់ឈ្មោះអីដែរ?

រឿនៈ ឈ្មោះ អ៊ូច ឡៃ។

ដានីៈ គាត់អាយុប៉ុន្មានដែរ?

រឿនៈ អាយុ៩៤ឆ្នាំ។

ដានីៈ ពូមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

រឿនៈ មាន៣នាក់។

ដានីៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

រឿនៈ ស្រី១ ប្រុស២។

ដានីៈ ពូសព្វថ្ងៃប្រកបមុខរបររកស៊ីធ្វើអីដែរ?

រឿនៈ ខ្ញុំធ្វើចំការ។

ដានី៖ ធ្វើចំការហ្នឹងធ្វើអីខ្លះទៅ?

រឿន៖ ដាំដំណាំដូចជាល្ង សណ្តែក ។

ដានី៖ ពូ ស្រុកកំណើតកើតជានៅភូមិឃុំស្រុកអីដែរ?

រឿន៖ ខ្ញុំនៅភូមិតាចេស ឃុំពេជ្រចង្វា ស្រុកបរិបូរ ខេត្តកំពង់ឆ្នាំង ។

ដានី៖ ពូស្គាល់ពូ ញ៉ែម អេន ទេ?

រឿន៖ អត់ដែលស្គាល់ទេ ។

ដានី៖ ឪពុកពូគាត់ឈ្មោះអីដែរ?

រឿន៖ ឪពុកខ្ញុំឈ្មោះ កែវ នឹង ។

ដានី៖ សព្វថ្ងៃគាត់នៅរស់ឬក៏ស្លាប់?

រឿន៖ គាត់ស្លាប់ហើយ ។

ដានី៖ ចុះម្តាយ?

រឿន៖ ម្តាយឈ្មោះ វ៉ាន់ ហ៊ុន គាត់នៅរស់ ។

ដានី៖ គាត់រស់នៅណាឥលូវ?

រឿន៖ គាត់នៅកំពង់ឆ្នាំង ។

ដានី៖ គាត់នៅស្រុកកំណើតរបស់គាត់?

រឿន៖ បាទ! នៅពន្លៃបរិបូរ ។

ដានី៖ នៅណា នៅពន្លៃ?

រឿន៖ បាទ! នៅឆានលិចទន្លេ ។

ដានី៖ ចុះពូមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់ទៅ?

រឿន៖ បងប្អូនបង្កើតមាន៨នាក់ ។

ដានី៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

រឿន៖ ស្រី១ ។

ដានី៖ អញ្ចឹងប្រុស៧នាក់?

រឿន៖ បាទ!

ដានី៖ ពូកូនទីប៉ុន្មាន?

រឿន៖ ខ្ញុំកូនទី៥ ។

ដានី៖ ពូកាលពីក្មេងៗមានបានទៅរៀនសូត្រនៅណាដែរ?

រឿន៖ អត់ កាលជំនាន់ហ្នឹងសាលារៀននៅជិតៗផ្ទះ កាលពីដើមគេហៅថ្នាក់ទី១០ ។

ដានី៖ ពូរៀនបានថ្នាក់ទី១០?

រឿន៖ បាទ! មានដែរសាលាកេលេស តែវាឆ្ងាយពីពន្លៃ ពីភូមិខ្ញុំមកសាលាកេលេស១២គីឡូ ជំនាន់ហ្នឹងមានស្អីទៀត ។

ដានី៖ ទី១០ ហ្នឹងគេហៅសាលាអីគេ?

រឿន៖ គេហៅសាលាកេលេសនៅភូមិពន្លៃ ហើយអត់ដែលបានមករៀនផង ។

ដានី៖ អញ្ចឹងពូរៀននៅថ្នាក់ទី១០ហ្នឹង រៀននៅសាលាណា?

រឿន៖ រៀននៅសាលាវត្តលោក ។

ដានី៖ រៀននៅសាលាវត្តលោក?

រឿន៖ បាទ!

ដានី៖ វត្តលោកនៅណា?

រឿន៖ នៅពេជ្រចង្វា ។

ដានី៖ ពូរៀនដល់ឆ្នាំណាបានឈប់ទៅ?

រឿន៖ ខ្ញុំរៀនដល់ឆ្នាំ៦៨បានឈប់ ។

ដានី៖ មូលហេតុអីបានជាពូឈប់នៅឆ្នាំ៦៨?

រឿន៖ កាលជំនាន់ហ្នឹងម៉ែឪក្រ ទៅណាឆ្ងាយក៏ទៅមិនដល់ ខ្ញុំរស់នៅជនបទដាច់ស្រយ៉ាល ។

ដានី៖ កាលហ្នឹងដល់ពេលពូឈប់រៀនហើយ មកធ្វើអីវិញទៅ?

រឿន៖ ប្រកបការងារធ្វើស្រែធម្មតា ។

ដានី៖ ធ្វើស្រែជាមួយឪពុកម្ដាយ ។

រឿន៖ ធ្វើជាមួយឪពុកម្ដាយ ។

ដានី៖ ហើយធ្វើអីទៀតក្រៅពីធ្វើស្រែ?

រឿន៖ អត់មានធ្វើអីទេ ខ្ញុំអាយុប្រហែលជា១៨-១៩ហ្នឹង ជំនាន់ឆ្នាំ៧២ហ្នឹងខ្ញុំធ្វើទាហានខ្មែរក្រហមរហូត ។

ដានី៖ អញ្ចឹងកាលឆ្នាំ៧២ពូធ្វើទាហាន?

រឿន៖ បាទ!

ដានី៖ ចុះមូលហេតុអីបានជាឆ្នាំ៧២ហ្នឹងពូធ្វើទាហាន?

រឿន៖ កាលជំនាន់ហ្នឹងនិយាយទៅតាមគេតាមឯង ហើយកាលហ្នឹងនៅក្មេងគេឃោសនារឿងតស៊ូ គេនិយាយរឿងតស៊ូវណ្ណៈហ្នឹង ដល់អញ្ចឹងចេះតែតាមគេទៅ ។

ដានី៖ កាលហ្នឹងដូចថាគេឃោសនាតស៊ូ ចុះលោកពូកាលហ្នឹងពូទៅធ្វើកងទ័ពខាងខ្មែរក្រហមហ្នឹង ពូទៅម្នាក់ឯង ឬក៏មានមិត្តភ័ក្ត្រឬក៏អ្នកស្រុកអ្នកភូមិទៅជាមួយដែរ?

រឿន៖ និយាយទៅវាទូទៅ កាលហ្នឹងវាភូមិដាច់ស្រយ៉ាល ហើយភូមិហ្នឹងខ្មែរក្រហមចូលដល់តាំងពីឆ្នាំ៧០ អញ្ចឹងវាទូទៅហ្មង ។

ដានី៖ ទូទៅហ្មង?

រឿន៖ បាទ!

ដានី៖ ពូចូលដំបូងទៅនៅណាទៅ?

រឿន៖ ដំបូង កាលហ្នឹងគេហៅអង្គភាពនៅស្រុក ធ្វើការក្នុងស្រុកហ្នឹងបានប្រហែលជា២ខែ ។

ដានី៖ ស្រុកអីគេ ស្រុកបរិបូរហ្នឹង?

រឿន៖ បាទ!

ដានី៖ គេហៅស្រុកលេខប៉ុន្មានទៅ?

រឿន៖ គេហៅស្រុកលេខ១០ ។

ដានី៖ បានរយៈពេល២ខែ?

រឿន៖ បាទ!

ដានី៖ បាន២ខែហើយពូទៅនៅណាទៀត?

រឿន៖ ខ្ញុំមកនៅកងពល គេហៅភូមិភាគកងពលទី១ ។

ដានី៖ ភូមិភាគប៉ុន្មាន?

រឿន៖ ភូមិភាគនារតី កាលហ្នឹងមិនទាន់ចែកភូមិភាគទេ គេនៅនារតីទាំងអស់ បើនិយាយទៅភូមិភាគបច្ចឹមក៏បានដែរ ។

ដានី៖ បច្ចឹមកងពលទី១?

រឿន៖ បាទ!

ដានី៖ ខែប៉ុន្មានដែលពូមកនៅ?

រឿន៖ ខ្ញុំចូលអង្គភាពតាំងពីថ្ងៃទី២ ខែ២ ឆ្នាំ៧២ ។

ដានី៖ អញ្ចឹងដល់ពេលមកនៅកងពលទី១ ពេលណាបានមកនៅកងពលទី១?

រឿន៖ កងពលទី១?

ដានី៖ បាទ!

រឿន៖ បើនិយាយទៅខ្ញុំមកនៅថ្ងៃទីប៉ុន្មានទេ ខ្ញុំមិនបានចាំទេ ។

ដានី៖ ខែ?

រឿនៈ តែគ្រាន់តែខ្ញុំអត់បាននៅឃុំផង នៅឃុំបានប៉ុន្មានខែ ហើយមកនៅភូមិភាគរហូត វាមិនសូវចាប់អារម្មណ៍បានគិតខែគិតថ្ងៃទេ ។

ដានីៈ មកនៅភូមិភាគ តែក្នុងកងពលទី១?

រឿនៈ បាទ!

ដានីៈ កងទ័ពដដែលទេ?

រឿនៈ កងទ័ពដដែល ។

ដានីៈ កាលហ្នឹងពូនៅក្នុងវរៈ ដូចថាយើងនៅក្នុងអនុសេនាធំ អនុសេនាតូច អនុសេនាធំអីប៉ុន្មានវរៈ?

រឿនៈ អនុសេនាធំ៣០៦ វរៈសេនាតូច១២០ ។

ដានីៈ វរៈសេនាធំ?

រឿនៈ វរៈសេនាធំវរៈ១៥ ។

ដានីៈ កាលហ្នឹងពូមានតួនាទីអីដែរ?

រឿនៈ ពីដំនាន់ហ្នឹងនៅយុទ្ធជន ។

ដានីៈ កាលហ្នឹងខាងកងពលទី១ គណៈកងពលទី១មានពីណាខ្លះ?

រឿនៈ កាលហ្នឹងវា ដែលប្រធានកងពលមាន បងម៉េត បងម៉េត រាល់ថ្ងៃគាត់នៅខាងសម្លូត ។

ដានីៈ ស៊ូ ម៉េត ហ្នឹងមែន?

រឿនៈ បែបហ្នឹងមិនដឹង ហើយ តាម៉េត ហ្នឹងឪពុកគាត់ឈ្មោះ តាម៉ាម៉ង់ គាត់នៅសម្លូត ហើយគាត់ខាងភូមិភាគណ៎រាល់ថ្ងៃ ។

ដានីៈ ឪពុកឈ្មោះ ម៉ាម៉ង់?

រឿនៈ បាទ!

ដានីៈ ឪពុកគាត់ធ្វើកាលហ្នឹង?

រឿនៈ អត់ដឹងដែរ ។

ដានីៈ ស្រុកកំណើតគាត់នៅជាមួយពូដែរ?

រឿនៈ អត់ទេ គាត់នៅខាងកំពង់ឆ្នាំងខាងត្បូង នៅខាងស្រុកកំពង់ត្រលាច ។

ដានីៈ ស្រុកកំពង់ត្រលាច?

រឿនៈ បាទ! ហើយមួយទៀតអនុគាត់ឈ្មោះ សឿង តែមិនដឹងឪពុកគាត់ឈ្មោះអី ។

ដានីៈ ឈ្មោះ សឿង?

រឿនៈ បាទ! គេហៅតែពេទ្យ សឿងៗ ។

ដានី៖ តែ២នាក់ហ្នឹងទេ?

រឿន៖ កាលហ្នឹងដូចមានអ្នកណាខ្លះទេ មិនសូវដឹងដែរ មិនសូវដែលបានឃើញមុខផង ។

ដានី៖ ចុះ តាសាន?

រឿន៖ តាសាន គាត់ក្រោយគេ គាត់ជំនាន់ហ្នឹងមិនមែនកងពលទេ ។

ដានី៖ គាត់មិនមែនកងពលទេ?

រឿន៖ បាទ! គាត់វរៈសេនាធំ ទាល់តែយើងសម័យសង្គ្រាមក្រោយ ។

ដានី៖ អញ្ចឹងកាលហ្នឹងមានតែ តាម៉េត ហើយនឹង តាសឿនទេ?

រឿន៖ បាទ!

ដានី៖ ចុះ តាល្វៃ?

រឿន៖ តាល្វៃ គាត់វរៈសេនាធំ១៥ ។

ដានី៖ ហើយ តាសាន គាត់វរៈសេនាធំប៉ុន្មានដែរ?

រឿន៖ តាសាន គាត់កាលជំនាន់ហ្នឹងគាត់នៅវរៈសេនាតូចនៅឡើយ ។

ដានី៖ គាត់អត់ទាន់មានឈ្មោះអីទេ?

រឿន៖ អត់ ។

ដានី៖ ចុះពូនៅក្នុងកងពលទី១ហ្នឹង ពេលហ្នឹងធ្វើអីខ្លះទៅ?

រឿន៖ សម័យសង្គ្រាមហ្នឹងដើរវៃ កងអន្តរាគមន៍ណាំ ដើរវៃគ្រប់កន្លែង ចាប់ពីថ្នល់ជាតិលេខ៤ មក មកទល់គ្នាព្រំប្រទល់ពោធិ៍សាត់ ។

ដានី៖ ពីផ្លូវជាតិលេខ៤ដល់ពោធិ៍សាត់ហ្នុង?

រឿន៖ បាទ! ស្រុកពោគោហ្នឹង ។

ដានី៖ វៃចាប់ពីឆ្នាំណាដល់ឆ្នាំណា?

រឿន៖ បើនិយាយទៅវៃតាំងពីយើង៧២មក តែវៃអញ្ចឹងទៅមួយខែពីរដកទៅវៃនៅនោះ វៃរហូតដល់ឆ្នាំ៧៤ ប៉ុន្តែកងចល័តទេ មិនមែនវៃឈរជើងទេ ។

ដានី៖ វៃរហូតដល់ឆ្នាំ៧៤?

រឿន៖ បាទ! ៧៤បានកម្លាំងហ្នឹងចាប់ផ្ដើមវៃភ្នំពេញវិញ ។

ដានី៖ ខែប៉ុន្មានបានចាប់ផ្ដើមវៃ?

រឿន៖ ចាប់ពីខែ១ ឆ្នាំ៧៥ហ្នឹង វៃពីមុំខាងត្បូងភ្នំប្រសិត ទៅជាប់គ្នាថ្នល់ជាតិលេខ៤ និយាយទៅចាប់ផ្ដើមពីថ្នល់រទេះភ្លើងចូលដល់សំរោង ចូលដល់ខាងពោធិ៍ចិនតុងហ្នឹងហ្នុង ។

ដានី៖ ចុះកាលហ្នឹងពូមានតួនាទីអីនៅ?

រឿនៈ ខ្ញុំអត់មានអីទេ ខ្ញុំនៅយុទ្ធជននៅឡើយ ។

ដានីៈ អញ្ចឹងពេលពូ ពូថាវ៉ៃចាប់តាំងពីឆ្នាំ៧២រហូត អញ្ចឹងដល់ពេលខែ១ ឆ្នាំ៧៥ហ្នឹងយើងវ៉ៃភ្នំពេញ?

រឿនៈ បាទ!

ដានីៈ ចាប់ពីខាងភ្នំប្រសិតរហូតដល់ខាងថ្នល់លេខ៤?

រឿនៈ បាទ!

ដានីៈ យើងវ៉ៃកាលហ្នឹងយ៉ាងម៉េចដែរ ពូអាចជួយរៀបរាប់ពីយុទ្ធសាស្ត្រយើងវ៉ៃគ្នា ពេលចូលភ្នំពេញយើងវ៉ៃយ៉ាងម៉េចទៅ?

រឿនៈ បើនិយាយទៅ កាលហ្នឹងដូចថាវ៉ៃព័ទ្ធជុំវិញភ្នំពេញហ្នឹងហ្នុង វ៉ៃហើយរំកិល វ៉ៃដាច់កន្លែងណារំកិលកន្លែងហ្នឹង ឈរជើងនៅកន្លែងហ្នឹង ។ វ៉ៃចូលដល់សំរោងជីកត្រង់សេនៅសំរោងហ្នឹងហ្នុង តែកាលហ្នឹងកម្លាំងច្រើនណាស់ទ័ព ។

ដានីៈ ទ័ពច្រើន?

រឿនៈ បាទ!

ដានីៈ ចុះអាវុធដូចថា គ្រាប់រំសេវ អាវុធអីយើងមានគ្រប់ទាំងអស់?

រឿនៈ មានគ្រប់គ្រាន់ទាំងអស់ បើនិយាយទៅកាលហ្នឹងវាកាំភ្លើងតូចកាំភ្លើងធំមាន អត់តែរថក្រោះដែលអត់មាន ។

ដានីៈ តែខាងទាហានមាន?

រឿនៈ ទាហានមាន ។

ដានីៈ ខាងយើងអត់មានទេ?

រឿនៈ ខាងយើងអត់មានទេ មានតែកាំភ្លើងធំ រកបានពីទាហានខាងក្នុង ។

ដានីៈ កាលហ្នឹងពូពេលដែលធ្វើសង្គ្រាមអត់មានត្រូវរបួសទេ?

រឿនៈ ខ្ញុំរបួសដែរ តែតិចតួច ។

ដានីៈ អត់មានទៅដេកពេទ្យទេ?

រឿនៈ ដេក ។

ដានីៈ អញ្ចឹងពូកាលហ្នឹងត្រូវរបួស តែត្រូវបន្តិចបន្តួចទេ?

រឿនៈ បាទ! ត្រូវក្បាលបន្តិច ហើយត្រូវជើង និយាយទៅជាត្រូវខ្លាំងដែរហ្នឹង ដេកពេទ្យ២-៣ខែ គ្រាន់តែវាអត់បាក់ជើងបាក់ដៃ ត្រូវមួយសារដែរ ។ រាល់ថ្ងៃខ្ញុំដាក់ចូលក្រឡួនពិការដែរហ្នឹង ព្រោះវាធ្វើទុកខ្ញុំរបួសក្បាល ខ្ញុំលែងធ្វើទាហានធ្វើអីហើយ ។

ដានី៖ អញ្ចឹងពូ ពេលដែលយើងវៃចូលដល់ទីក្រុងភ្នំពេញ យើងវៃចូលតាមច្រកណាទៅ?

រឿន៖ អាហ្នឹងវាកងពល បើនិយាយទៅតាមកងពលតាមច្រក ខ្ញុំចាប់ពីគេហៅវាំសំរោងហ្នឹង ចាប់ពីថ្នល់ជាតិលេខ៤ដល់វាំសំរោងថ្នល់រទេះភ្លើងហ្នឹង ចូលចំពោធិ៍ចិនតុង ហើយកងពលគេផ្សេងៗគេចាប់ពីថ្នល់ជាតិលេខ៤-៣ លេខអីអញ្ចឹងទៅ លេខ២អញ្ចឹងទៅ អាហ្នឹងចូលមកស្រករគ្នាអញ្ចឹងទាំងអស់គ្នាទៅ អាហ្នឹងយើងដឹងមុខសញ្ញាយើងចូលទៅ។

ដានី៖ ហើយលោកពូ ពេលដែលយើងបានជ័យជំនះនៅទីក្រុងភ្នំពេញហើយ កាលហ្នឹងយ៉ាងម៉េចទៅ យើងមកនៅណាទៅ?

រឿន៖ ខ្ញុំពេលនោះ កងទ័ពស្រួចគឺអត់មាននៅតាមភូមិទេ កម្លាំងមួយចំនួនគឺនៅតាមថ្នល់ជាតិលេខ៣ ចាប់ពីផ្សារកន្ទួតទៅតាមថ្នល់ជាតិលេខ៣ដល់ស្វាគោ អាហ្នឹងមួយចំនួន ម៉ាផ្នែក ហើយមួយផ្នែកទៀតទៅការពារនៅកោះកុងនឹងព្រៃនុប ការពារសមុទ្រ។

ដានី៖ ហើយចុះពូទៅនៅខាងណាដែរ?

រឿន៖ ខ្ញុំនៅខាង ដែលគេហៅកោះសេះ នៅម្តុំយើងព្រៃនុបដែរ តែទៅខាងកោះសេះ ទៅត្បូងវិញ។

ដានី៖ អញ្ចឹងកាលហ្នឹងពេលដែលយើងបែកភ្នំពេញឆ្នាំ៧៥ហើយ កងពលទី១ហ្នឹងយើងបែងចែកគ្នា?

រឿន៖ បាទ! មួយមកការពារនៅកោះកុង នៅតាមព្រំដែនមកទល់គ្នាក្នុងយៃនេះ។

ដានី៖ បែកជាពីរ?

រឿន៖ បាទ!

ដានី៖ បែកជាពីរ មួយផ្នែកនៅខាង?

រឿន៖ មួយផ្នែកនៅខាងព្រៃនុបការពារមួយជួរ គេហៅកោះខ្យង មួយជួរកោះសេះកោះអីនៅខាងត្បូងនេះ អាហ្នឹងខ្ញុំនៅខាងហ្នឹង។

ដានី៖ នៅម្តុំកោះខ្យង ហើយនឹងកោះសេះអីហ្នឹង?

រឿន៖ បាទ!

ដានី៖ ហើយមួយផ្នែកទៀត?

រឿន៖ មួយផ្នែកទៀត មួយកងពលហ្នឹងដែរគេជួយធ្វើការក្នុងការដ្ឋាន លើកជាទំនប់ លើកអីម្តុំយើងព្រៃនុបហ្នឹង អូរចំណា ព្រៃនុប។

ដានី៖ ប៉ុន្តែមួយផ្នែកទៀត មាននៅពោធិ៍ចិនតុងដែរអត់?

រឿនៈ មួយផ្នែកទៀត កាលហ្នឹងវាមានបែកចែកផ្នែកគ្នា កាលហ្នឹងដកកងពល បងម៉េត ហ្នឹងមកនៅ នៅពោធិ៍ចិនតុង ។

ដានីៈ ដក តាម៉េត ហ្នឹង?

រឿនៈ បាទ! អញ្ចឹងវាមួយកងពល គេមាន៣វរៈសេនាធំ វរៈសេនាធំ គេហៅវរៈសេនាធំ១៧ ហ្នឹងគឺកង តាម៉េត ហ្នឹងឯង អញ្ចឹងកាលហ្នឹងមាន អ៊ំសេង មេឃុំរាល់ថ្ងៃហ្នឹងគាត់មកឈរជើង ។

ដានីៈ មកឈរជើងនៅណា?

រឿនៈ ខាងពោធិ៍ចិនតុង ។

ដានីៈ ខាងពោធិ៍ចិនតុង?

រឿនៈ បាទ! គាត់ខាងជើងអាកាស អ៊ំឆន មេឃុំរាល់ថ្ងៃហ្នឹង ។

ដានីៈ គាត់ឈ្មោះ អ៊ំសេង ហៅអ៊ំឆន?

រឿនៈ បាទ! អ៊ំសេង គាត់វរៈសេនាធំ នៅជាមួយគ្នា ។

ដានីៈ អញ្ចឹងដល់ពេលបែក៧៥ទៅ ម៉ាផ្នែកនៅពោធិ៍ចិនតុង ហើយម៉ាផ្នែកទៀតនៅការពារខាងសមុទ្រ?

រឿនៈ បាទ!

ដានីៈ ខាងព្រែនុប ខាងកោះខ្យង ទៅខាងកោះកុងអញ្ចឹងទៅ?

រឿនៈ បាទ!

ដានីៈ អញ្ចឹងពេលហ្នឹង តាម៉េត គាត់បង្កើតជាកងពលមួយទៀត?

រឿនៈ កាលហ្នឹងបង្កើតជាកងពលមួយទៀត?

ដានីៈ គេហៅកងពលអី?

រឿនៈ បើនិយាយទៅខ្ញុំអត់ដឹងផង ដល់បែកគ្នាខ្ញុំអត់ដឹងថាកងពលអីផង ។

ដានីៈ អញ្ចឹងពូនៅកងពលម៉េច?

រឿនៈ ខ្ញុំនៅកងពលទី១ដដែល ។

ដានីៈ កងពលទី១ដដែល?

រឿនៈ បាទ!

ដានីៈ កងពលរបស់ភូមិភាគបច្ចឹមដដែល?

រឿនៈ បាទ! ដដែល ។

ដានីៈ ចុះមន្ទីរកងពលនៅណា?

រឿនៈ	មន្ទីរកងពលកាលហ្នឹងនៅព្រៃនុប ។

ដានីៈ	មិនមែននៅលង្វែកទេ?

រឿនៈ	លង្វែកក៏នៅ ហើយព្រៃនុបក៏នៅ នៅពីរកន្លែង ។

ដានីៈ	នៅពីរកន្លែង?

រឿនៈ	បាទ! តែកន្លែងធំរបស់គាត់នៅលង្វែក ។

ដានីៈ	កន្លែងធំនៅលង្វែក?

រឿនៈ	បាទ! ហើយកន្លែងមួយទៀតនៅព្រៃនុប នៅជិតវត្តព្រៃនុប គេហៅភូមិបត់សេមាន់ហ្នឹង គាត់ចំណាំទៅស្នាក់នៅហ្នឹង នៅម៉ុំហ្នឹង កន្លែងសាលាចាម ។

ដានីៈ	អញ្ចឹងកងពលទី១ពេលដែល តាម៉េត ដកទៅ គណៈកងពលមានពីណាខ្លះ កងពលទី១ពេលបែកឆ្នាំ៧៥ហ្នឹង?

រឿនៈ	ពេលដក តាម៉េត ទៅវាកងពលកាលហ្នឹង ឈ្មោះ តានាង តែ តានាង ហ្នឹងបាត់ខ្លួនតាំងពីឆ្នាំ៧៩ កាលហ្នឹងដកពេល តាម៉េត ទៅមាន តានាង ហ្នឹងឯង តាសឿង គាត់ប្រធាន ។

ដានីៈ	តាសឿង ហ្នឹងគាត់ប្រធាន?

រឿនៈ	បាទ! តែកាលហ្នឹងដក តាសឿង មកភូមិភាគឧត្តរ អញ្ចឹងឡើងដំណាងឈ្មោះ តានាង ។

ដានីៈ	ឡើង តានាង?

រឿនៈ	បាទ!

ដានីៈ	តានាង តែម្នាក់ទេ?

រឿនៈ	បាទ! តានាង ហើយតាអីទេភ្លេចឈ្មោះបាត់ហើយ ។

ដានីៈ	ចុះ តាសាន គាត់នៅហ្នឹងដែរឬក៏ដកទៅណា?

រឿនៈ	តាសាន កាលហ្នឹងគាត់នៅពោធិ៍ចិនតុង គាត់នៅជាមួយ តាម៉េត ។

ដានីៈ	ពូអត់ឃើញគាត់នៅក្នុងកងពលជាមួយទេ?

រឿនៈ	អត់ទេ តាសាន ហ្នឹងពូនិយាយពី តាសាន ណា?

ដានីៈ	តាសាន គាត់នៅប្រម៉ោយ កែវ សាន?

រឿនៈ	តាសាន គាត់នៅពោធិ៍ចិនតុង ។

ដានីៈ	ពូស្គាល់គាត់ដែរអត់?

រឿនៈ	ស្គាល់គាត់ដែរ ។

ដានីៈ	ប៉ុន្តែកាលយើងធ្វើសង្គ្រាម ឃើញគាត់នៅក្នុងកងពលហ្នឹងដែរ?

រឿនៈ	នៅជាមួយទាំងអស់គ្នាហ្នឹង ។

ដានី: ប៉ុន្តែដល់ពេលបែកឆ្នាំ៧៥ ពេលដែលយើងរំដោះឆ្នាំ៧៥?

រឿន: បែកឆ្នាំ៧៥ គេបំបែកក្នុងមួយកងពលគេបំបែកជាពីរ មួយមកនៅពោធិ៍ចិនតុង មួយទៀតនៅតាមព្រំដែន។

ដានី: ប៉ុន្តែអត់ដឹងថា តាសាន គាត់នៅណាទេ?

រឿន: មិនដឹងគាត់នៅណាទេ អត់ដឹងដែរ។

ដានី: ប៉ុន្តែ តាសឿង?

រឿន: តាសឿង គាត់នៅកោះកុងទេ តែស្នាក់ការគាត់នៅលង្វែក។

ដានី: នៅលង្វែក?

រឿន: បាទ! តែយើងឆ្នាំ៧៨ហើយ បានដកគាត់ទៅខត្តរ គាត់ទៅនៅក្រោយទេ។

ដានី: គាត់ទើបតែទៅនៅក្រោយទេ?

រឿន: បាទ!

ដានី: តែចំពោះពូ ពូមកនៅខាងព្រៃនុប ខាងកោះខ្យង?

រឿន: បាទ! ខ្ញុំមកនៅរហូតដល់ឆ្នាំ៧៩បែកហ្នឹងហ្មង។

ដានី: ចុះពូកាលហ្នឹងនៅព្រៃនុប នៅកោះខ្យងហ្នឹងយ៉ាងម៉េច មួយវរៈសេនាធំ?

រឿន: បាទ! នៅមួយវរៈសេនាធំ។

ដានី: របស់ភូមិភាគ...?

រឿន: របស់ភូមិភាគបច្ចឹម។

ដានី: កាលហ្នឹងពីណាគេនៅគ្រប់វរៈសេនាធំនៅកោះខ្យង?

រឿន: វរៈសេនាធំកាលហ្នឹងវាច្រើនផ្នែកណាស់ មុនដំបូង អ៊ឹផល ផល យើងនៅនេះហ្នឹង។

ដានី: ឯក សុផល ហ្នឹង?

រឿន: បាទ!

ដានី: ឯក សុផល ហ្នឹងគាត់វរៈសេនាធំ?

រឿន: បាទ! គាត់វរៈសេនាធំ។

ដានី: វរៈសេនាធំអីគេហ្នឹង?

រឿន: ដល់ក្រោយមកគាត់ចេញទៅខាងកោះកុងទៅ ហើយកាលនោះតាអីទេ ដល់បែកគ្នាយូរក្មេចដល់មនុស្សបែកគ្នាយូពេកភ្លេចឈ្មោះមនុស្សបាត់។

ដានី: ចុះអ៊ឹផល គាត់នៅវរៈសេនាធំហ្នឹងហើយ គេដកគាត់ទៅណា?

រឿន: គាត់គេឲ្យគាត់ទៅធ្វើគណៈតំបន់ ចៅហ្វាយខេត្តកោះកុង។

ដានី:	ឲ្យទៅជាគណៈតំបន់នៅខាងកោះកុង?

រឿន:	បាទ!

ដានី:	គណៈតំបន់លេខប៉ុន្មាន?

រឿន:	មិនដឹងលេខប៉ុន្មានទេ ។

ដានី:	លេខាតំបន់?

រឿន:	បាទ!

ដានី:	ចុះពូកាលហ្នឹងមានតួនាទីអីដែរ?

រឿន:	ខ្ញុំចូលឆ្នាំ៧៨ ខ្ញុំកាន់អគ្គភាព អគ្គភាពគេហៅអនុសេនាតូចពីដើម ។

ដានី:	ចុះកាលពីដំបូង កាលឆ្នាំ៧៥?

រឿន:	អត់មានអីទេ តែដល់ឆ្នាំ៧៥ហ្នឹងខ្ញុំកាន់ជាមេក្រុម ឆ្នាំ៧៧-៧៨ខ្ញុំកាន់ជាអនុសេនាតូច ។

ដានី:	ចុះពូកាលនៅព្រៃនុប នៅកោះខ្យងអីហ្នឹងធ្វើអីខ្លះទៅ?

រឿន:	នាទីខ្ញុំ?

ដានី:	ការងាររបស់ពូ?

រឿន:	ការងាររបស់ខ្ញុំការពារព្រំដែន ។

ដានី:	ការពារព្រំដែន?

រឿន:	បាទ! ការពារព្រំដែនទឹក ។

ដានី:	នៅចន្លោះណាខ្លះ?

រឿន:	នៅម្តុំគេហៅកោះខ្យង ពន្លិច ម៉ាដួរគេហៅព្រែកចាកអីហ្នឹង កោះថ្មី កោះពិសេសហ្នឹង ។

ដានី:	ក្រែងកងពល១៦៤ គេផ្សេង?

រឿន:	កងពល១៦៤គេនៅទល់មុខខាងនោះ ហើយខ្ញុំមកនៅខាងនេះវិញ ខ្ញុំមកក្រោយនេះវិញ ១៦៤គេនៅកោះថ្មីដែរ តែគេការពារមុខទៅនោះ ហើយខ្ញុំឡើងជាយមកខាងដើងវិញ មកម្តុំឆ្នេរសមុទ្រខាងដើងនេះ ។

ដានី:	អាហ្នឹងរបស់ភូមិភាគ?

រឿន:	បាទ! របស់ភូមិភាគ ។

ដានី:	ចុះរបស់ តាមុត?

រឿន:	របស់ តាមុត គាត់ខាងអន្តរាគមន៍ ។

ដានី:	អញ្ចឹងពូនៅលើគោក ឬក៏នៅលើកោះ?

រឿនៈ នៅលើគោក និយាយទៅដូចថាយើងចតធ្វើរោងតាមព្រែកអញ្ចឹងទៅ តាមទឹក យើងធ្វើរោងធ្វើអីនៅក្នុងទឹកអញ្ចឹងទៅ ការពារក្នុងទឹក ។

ដានីៈ ការពារក្នុងទឹក?

រឿនៈ ហ្នឹងហើយ ។

ដានីៈ ចុះពូកាលនៅកោះខ្យងនៅដែរ?

រឿនៈ ខ្ញុំនៅ កាលហ្នឹងខ្ញុំនៅរហូតតាំងពីឆ្នាំ៧៥មករហូតដល់ឆ្នាំ៧៩ ។

ដានីៈ ខ្ញុំធ្លាប់ទៅដល់កោះខ្យងដែរ ចូលតាមអូរចំណា ។

រឿនៈ បាទ! មុំហ្នឹងខ្ញុំស្គាល់ទាំងអស់ហ្នឹង ។

ដានីៈ ពូស្គាល់ទាំងអស់?

រឿនៈ បាទ! ចាប់ពីព្រែកកំពង់ស្មាច់ពីកើតអញ្ចឹងទៅ ទៅជិតរាមហ្នឹងខ្ញុំស្គាល់ តាមឆ្នេរកាលហ្នឹងខ្ញុំនៅតាមជាយៗហ្នឹង ។

ដានីៈ ចុះប្រជាជននៅច្រើនទេកាលហ្នឹង?

រឿនៈ កាលហ្នឹងប្រជាជនគាត់នៅតែតាមម្តុំព្រៃនុបក៏នៅ ម្តុំស្រែចាមក៏នៅ បើនិយាយទៅម្តុំតាមសមុទ្រហ្នឹងគាត់អត់មាននៅទេ នៅតាមថ្នល់ជាតិនេះ ។

ដានីៈ ចុះកន្លែងកោះខ្យងកាលហ្នឹងខ្ញុំទៅមានប្រជាជនប្រាប់ថា កន្លែងហ្នឹងដូចថាមានមន្ទីរសន្តិសុខមួយដែរ នៅកន្លែងកោះខ្យង?

រឿនៈ កោះខ្យងហ្នឹង គេមានកន្លែងមន្ទីរគេមួយ ។

ដានីៈ មន្ទីររបស់កងពលមែន?

រឿនៈ បាទ! មន្ទីររបស់កងពល ។

ដានីៈ មន្ទីររបស់កងពលរបស់ពូមែន?

រឿនៈ បាទ!

ដានីៈ កន្លែងកោះខ្យងហ្នឹង?

រឿនៈ បាទ! កន្លែងកោះខ្យង ។

ដានីៈ កន្លែងមន្ទីរសន្តិសុខដូចថា សម្រាប់ដាក់អ្នកយ៉ាងម៉េច សមាសភាពយ៉ាងម៉េចទៅ?

រឿនៈ មិនដែលឃើញមានសមាសភាពអីធំដង ច្រើនតែដាក់ដូចថា មនុស្សសិលធម៌អីបន្តិចបន្តួចហ្នឹង អត់មានមន្ទីរអីធំដុំទេ ដូចថាគេធ្វើសម្រាប់ក្នុងអង្គភាព ព្រោះកាលហ្នឹងវិន័យរបស់កងទ័ពខ្លាំងណាស់ វិន័យរបស់កងទ័ពជាងលោកសង្ឃទៀតកាលហ្នឹង ប្រកាន់ខ្លាំងណាស់ បើ

យើងធ្វើខូចខិលស្រីញីអត់បានទេជំនាន់ហ្នឹង  អញ្ចឹងបើយើងខូចខិលគេយកទៅដាក់ក្នុងមន្ទីរ មិនមែនមន្ទីរអីធំដុំទេ ។

ដានី: ប៉ុន្តែច្រើនតែដាក់កងទ័ពទេ?

រឿន: បាទ!

ដានី: ចុះប្រជាជនអត់មានទេ?

រឿន: អត់មានទេ ។

ដានី: កងទ័ពក្នុងអង្គភាពរបស់ពូ ឬក៏កងទ័ពមកពីកន្លែងផ្សេង?

រឿន: អត់ទេ  កងទ័ពក្នុងហ្នឹងហ្មង  ដូចថាកាលហ្នឹងគេវិន័យ  ព្រោះរឿងស្រីញីអត់ឲ្យប៉ះពាល់ទេ រឿងលួច រឿងឆក់ រឿងប្ចូន់អីរបស់ប្រជាជនអត់សោះ អត់ទេ វិន័យខ្លាំងណាស់ ។

ដានី: អាហ្នឹងគេហៅអីគេ អាកន្លែងហ្នឹង?

រឿន: បាទ?

ដានី: កន្លែងកោះខ្យងគេហៅអីគេ?

រឿន: អត់មានដាក់ឈ្មោះជាអីផង ។

ដានី: គេហៅមន្ទីរសន្តិសុខកោះខ្យងឬក៏អីផ្សេង?

រឿន: អត់មានឈ្មោះអីផង ព្រោះអត់ឃើញមានគេដាក់អីផង ។

ដានី: ប៉ុន្តែយើងនាំគ្នាហៅ គេដឹងដែរ?

រឿន: គេដឹង ។

ដានី: គេដឹងថាយ៉ាងម៉េច?

រឿន: បើនិយាយទៅកន្លែងហ្នឹងគេដឹងតែកងទ័ពទេ ប្រជាជនអត់ដឹងទេ ។

ដានី: កន្លែងហ្នឹងប្រជាជនអត់ដឹងទេ?

រឿន: អត់ដឹងទេ ។

ដានី: ចុះនៅពេលដែលមានអ្នកដែលជាប់នៅកន្លែងហ្នឹង  គេមានដូចជាដាក់ខ្នោះ  ដាក់ច្រវាក់ដាក់អីទេ?

រឿន: មានដាក់ដែរហ្នឹង ។

ដានី: អ៎! គេមានដាក់ដែរ?

រឿន: បាទ! ដាក់ ។

ដានី: ធំទេកន្លែងហ្នឹង?

រឿន: អត់ទេ កន្លែងហ្នឹងមិនធំទេ កន្លែងប៉ុនហ្នឹង ប៉ុនផ្ទះ ។

ដានី: ប៉ុនផ្ទះនេះ?

រឿន: បាទ! ប្រហែល១០ម៉ែត្រ ៤ជ្រុង គ្មានមនុស្សណាផង មានតែ២-៣នាក់ហ្នឹង ។

ដានី: ពូធ្លាប់យាមនៅហ្នឹងដែរអត់?

រឿន: អត់ទេ ខ្ញុំអត់ដែរទេ ។

ដានី: ប៉ុន្តែយើងធ្លាប់ឆ្លងកាត់ទេ?

រឿន: ធ្លាប់ឆ្លងកាត់ ។

ដានី: ពូឃើញកន្លែងហ្នឹងដែរ?

រឿន: បាទ! បើកន្លែងខ្ញុំនៅខាងលិច ។

ដានី: អញ្ចឹងកន្លែងគុកនៅកោះខ្យងហ្នឹងមិនមែនរបស់ តាមុត ទេ របស់អង្គភាពពូទេ?

រឿន: របស់អង្គភាពទេ មិនមែនរបស់ តាមុត ទេ អាហ្នឹងនិយាយទៅគេមានតាមអង្គភាព តាមកន្លែងរបស់គេ កន្លែងណាក៏គេមានដែរ ។

ដានី: អញ្ចឹងសម្រាប់ដូចថាកងទ័ពដែលខុសសិលធម៌ ស្រីញី ឬក៏គាត់ខុសអីផ្សេងៗ ខុសវិន័យអីហ្នឹងគេយកទៅដាក់ហ្នឹង?

រឿន: បាទ! គេយកទៅដាក់នៅហ្នឹង និយាយទៅមនុស្សកាលហ្នឹងគេមានការប្រជុំរហូត អញ្ចឹងក្នុង៣ថ្ងៃគេត្រូវប្រជុំ ដូចថា៣នាក់អញ្ចឹងក្នុងមួយក្រុមគេបំបែកជាពួក ក្នុងមួយពួកហ្នឹងគេហៅ៣នាក់ នៅហ្នឹងណា៎ អញ្ចឹងក្នុង៣ថ្ងៃគេប្រជុំហើយ ពួកគេហ្នឹង ៣នាក់គ្នាគេហ្នឹងគេប្រជុំហើយ តែដល់មួយអាទិត្យគេហៅក្នុងក្រុមទៅប្រជុំ កាលណាគេប្រជុំគេនិយាយតែការងារហ្នឹង ហើយរឿងសិលធម៌ បើអ្នកឯងខូចខិលគឺក្រុមហ្នឹងហើយ គេហៅថាស្វាយតិះទៀនកាលពីដើម អញ្ចឹងបើយើងជួយកែលំអរទាំងអស់គ្នា អញ្ចឹងឲ្យមនុស្សហ្នឹងវាកែខ្លួន ដើម្បីកុំឲ្យធ្វើខុស តែបើយើងមិនស្តាប់អាហ្នឹងវាច្រើនទៅ គេយកទៅដាក់ ។

ដានី: តែមានគេសម្លាប់ទេ?

រឿន: អត់ដឹង ដូចអត់មានទេ ។

ដានី: ពូអត់ដឹងទេ?

រឿន: អត់ដឹងផង ។

ដានី: អត់ដឹងថាមានគេសម្លាប់ទ?

រឿន: អត់ដឹងទេ ។

ដានី: ពីណាគេអ្នកគ្រប់គ្រងនៅហ្នឹង?

រឿន: មេទាហានហ្នឹង?

ដានី៖ បាទ! ដូចថាយើងអ្នកទទួលខុសត្រូវកន្លែងកោះខ្យងហ្នឹង?

រឿន៖ កោះហ្នឹងវាតាមវរៈ ទាំងអស់ហ្នឹងមិនដឹងវរៈណាទេ វរៈសេនាតូចគេ ។

ដានី៖ ចុះវរៈសេនាធំនៅកន្លែងណា?

រឿន៖ វរៈសេនាធំកាលហ្នឹង និយាយទៅនៅកន្លែងណាទេ កាលហ្នឹងដូចវាភ្លេចទៅណា៎ វរៈសេនាធំនៅនេះទេ នៅបត់សេមាន់ទេ ជាប់មន្ទីរកងពលទេ ព្រោះមន្ទីរកងពលកាលហ្នឹងគាត់មិនមែននៅជាប់ទេ គាត់ចល័តរហូត គាត់ចល័តទៅនៅនេះនៅនោះ ។

ដានី៖ នៅណា នៅមន្ទីរកងពល?

រឿន៖ មន្ទីរកងពលកាលហ្នឹងមកលង្វែក ជួនកាលគេទៅហ្នឹងទៅ ៨-១០ថ្ងៃមកនៅលង្វែកនេះមក អាហ្នឹងមន្ទីរកងពលណា៎ ។

ដានី៖ នៅបត់សេមាន់ហ្នឹង?

រឿន៖ នៅបត់សេមាន់ហ្នឹងច្រើនតែវរៈសេនាធំគេនៅហ្នឹងឯង ។

ដានី៖ បត់សេមាន់ហ្នឹងនៅម្តុំណា?

រឿន៖ បត់សេមាន់នៅខាងលើវត្តព្រៃនុបបន្តិច ។

ដានី៖ ខាងលើវត្តព្រៃនុបបន្តិច?

រឿន៖ បាទ! អាចុងទំនប់ហ្នឹង អាហ្នឹងគេហៅភូមិសេមាន់ហើយ ។

ដានី៖ អញ្ចឹងពូដូចថានៅធ្វើវេងនៅក្នុងទឹកហ្នឹងហ្នង?

រឿន៖ បាទ!

ដានី៖ យើងការពារចាំមើលអីទៅ?

រឿន៖ យើងការពារព្រំដែន ។

ដានី៖ ដែលឃើញមានខ្មាំងចូលមកទេ?

រឿន៖ វាមិនដែលមានស្អីណាផង ដល់ពេលចូលគឺចូលធំហ្នឹងហ្នង ។

ដានី៖ ដល់ពេលចូលគឺចូលធំហ្នង?

រឿន៖ បាទ! កាលហ្នឹងអត់ដែលមានអីផង ។

ដានី៖ ចុះក្រៅពីការពារ មានបន្តរបង្កើនផលអីទៀតទេ?

រឿន៖ អាហ្នឹងមានអង្គភាព អង្គភាពដែលគេរៀបចំ មានអ្នកការពារខាងមុខ មានអ្នកមកក្រោយ អ្នកមកក្រោយនៅមូលដ្ឋានគ្មានធ្វើអីក្រៅពីធ្វើស្រែទេ កាលហ្នឹងវាដូចថា អង្គភាពនៅកន្លែងណាធ្វើកន្លែងហ្នឹង ដូចនៅសមុទ្រអញ្ចឹង ដល់ពេលអីដីធ្វើមកធ្វើនៅខាងព្រៃនុបអញ្ចឹងទៅ ហើយគ្រាន់អ្នកនៅក្រោយនេះ នៅលង្វែកនេះធ្វើនៅលង្វែកនេះទៅ ។

ដានី៖ អញ្ចឹងកន្លែងពូហ្នឹងធ្វើស្រែធ្វើអីទៅ?

វឿន៖ ខាងខ្ញុំអត់ទេ គ្រាន់តែដាំដាដំណាំដាអីទេ ដាំដូចដាដំឡូង ព្រោះកាលហ្នឹងនៅណាធ្វើហ្នឹងអត់មានប្រកាន់ថាកងទ័ពការពារព្រំដែនអីអត់ទេ ត្រូវស្អូង១ ។

ដានី៖ ប៉ុន្តែអត់ដែលឮថាពួកខ្មាំងអីចូលមក ហើយយើងចាប់បានយកមកដាក់ខ្នោះ?

វឿន៖ អត់មានទេ ។

ដានី៖ ប្រជាជនក៏អត់ដែរ?

វឿន៖ ប្រជាជន ខ្ញុំមិនសូវដឹងដែរ មិនដឹងកន្លែងគេទីណាទេ ខ្ញុំមិនសូវដឹងដែរ ។

ដានី៖ ដូចថាប្រសិនបើប្រជាជនខុសអី ដូចថាគាត់ធ្វើអីខុស ខុសសិលធម៌ខុសអី ខុសនយោបាយអីគេយកមកដាក់កោះខ្យងដែរ?

វឿន៖ អត់ទេ អាហ្នឹងជាកន្លែងរបស់កងទ័ព គេធ្វើហ្នឹងដូចថាខាងតំបន់ ខាងទ័ពតំបន់ ខាងស្រុកអីគេវិញ ខាងឈ្លបភូមិឈ្លបឃុំគេវិញអាហ្នឹង ហើយយើងទ័ពស្រួចដឹងតែការពារព្រំដែនទេ ។

ដានី៖ ចុះកាលហ្នឹងហូបចុកអីយ៉ាងម៉េចដែរ កងទ័ព?

វឿន៖ កងទ័ពកាលហ្នឹងមិនដែលឮលំបាកផង ។

ដានី៖ អត់ដែលពិបាកទេ?

វឿន៖ អត់ដែលលំបាកទេ តែគ្រាន់តែកាលហ្នឹង វាត្រង់ថាទាហានដូចជាខ្ញុំអីគេមិនឲ្យមកលេងផ្ទះ ។

ដានី៖ គេអត់ឲ្យមកលេងផ្ទះទេ?

វឿន៖ បាទ! អត់ឲ្យមកលេងទេ គ្រាន់តែយើងដឹងប៉ុណ្ណឹង តែបើសម្រាប់ទាហានដូចខ្ញុំអត់ដឹងអីទេ និយាយទៅគ្មានស្រីគ្មានញីអីទេ សុទ្ធតែប្រុស១នៅការពារ និយាយទៅកាលហ្នឹងប្រជាជនអីអត់មានឲ្យច្របូកច្របល់ទេ ។

ដានី៖ ចុះពូធ្លាប់បានមកលេងផ្ទះទេ?

វឿន៖ អត់ដែលមកលេងផ្ទះ ។

ដានី៖ យើងអត់ចង់មកលេងឬក៏ម៉េច?

វឿន៖ អត់ទេ កាលហ្នឹងច្បាប់អត់សុំបានមកលេងទេ ។

ដានី៖ គេអត់ឲ្យច្បាប់យើងសុំមកលេងផ្ទះ?

វឿន៖ អត់ ។

ដានី៖ ប៉ុន្តែពូមានដែលសុំគេទេ?

វឿន៖ សុំដែរ តែគេថាអត់ ដល់ហើយអត់ហ្នងទៅ ។

ដានី៖ សុំពីណាគេ?

រឿនៈ សុំមេក្រុមមេកងគេហ្នឹង អាហ្នឹងកាលហ្នឹងច្បាប់ទាល់តែសុំបន្ត អញ្ចឹងបើយើងនៅក្រុមណាទាល់តែសុំមេក្រុមហ្នឹង ហើយមេក្រុមហ្នឹងទៅសុំមេកងគេបន្តទៀត អញ្ចឹងវាតាមខ្សែណ៎ា ។

ដានីៈ អញ្ចឹងពូសុំគេ គេថាអត់ឲ្យមក?

រឿនៈ អត់ឲ្យមកទេ ។

ដានីៈ មូលហេតុអីបានជាគេអត់ឲ្យមក?

រឿនៈ បើនិយាយទៅកាលហ្នឹងកងទ័ពវាមានការងារគ្រប់គ្នា អ្នកការពារគឺការពារទៅ អ្នកធ្វើស្រែលើកទំនប់ ជីកប្រលាយអីគេមានការងាររបស់គេអញ្ចឹងទៅ ។

ដានីៈ ពូ នៅវរៈសេនាធំដែលពូផ្លាស់ទៅហ្នឹង បន្ទាប់ពី ជល គាត់ផ្លាស់ទៅធ្វើគណៈតំបន់ខាងកោះកុងហ្នឹង ពីណាគេឡើងជំនួស?

រឿនៈ ភ្លេចឈ្មោះបាត់ហើយ មិនដឹងជាឈ្មោះអីទេ ព្រោះបែកគ្នាទៅភ្លេចគាត់ ហើយបែកគ្នាបែករហូតតាំងពី៧៩មក បាត់មុខតាហ្នឹងបាត់ហើយ មិនដឹងទៅណាទេ ។

ដានីៈ ចុះពូមានធ្លាប់ឡើងមកភ្នំពេញដែរទេ?

រឿនៈ ខ្ញុំអត់ដែលទេ ។

ដានីៈ ចុះពេលគេប្រជុំកងពលអី គេប្រជុំនៅណាទៅ?

រឿនៈ ប្រជុំកងពល បើរៀនសូត្រអីកងពលឡើងទៅពេលហ្នឹងហ្នង គេមានសាលាគេសម្រាប់ប្រជុំយើងព្រៃនុបហ្នឹង នៅហ្នឹងគេហៅស្ទឹងទេ ហួសពីបត់សេមាន់បន្តិចទៅ កន្លែងហ្នឹងធ្វើសាលាធំសម្រាប់រៀនសូត្រ កងទ័ពគេហៅទៅជុំគ្នានៅហ្នឹង តាំងពីកោះកុង តាំងពីអ្នកនៅខាងធ្វើកោះខ្យងហ្នឹងទាំងអស់ ។

ដានីៈ កាលហ្នឹងពូមានប្រពន្ធនូវ?

រឿនៈ អត់ទាន់មានទេ ។

ដានីៈ ចុះពូ មេញពូមានប្រសាសន៍ថាកាលឆ្នាំ៧៧ហ្នឹងពូបានឡើងឋានៈ?

រឿនៈ បាទ!

ដានីៈ ពេលហ្នឹងសកម្មភាពយ៉ាងម៉េចបានជាពូបានឡើងឋានៈ?

រឿនៈ ដូចថាតាមការងារយើង យើងសកម្មធ្វើការងាររីកចំរើនទៅគេចេះតែឲ្យយើងឡើង ។

ដានីៈ កាលហ្នឹងអនុសេនាធំឬអនុសេនាតូច?

រឿនៈ ធ្វើអនុសេនាតូច បើនិយាយទៅកម្លាំងដែលចាស់ៗទៅខាងព្រំដែនខាងកើតអស់ហើយហើយអាអ្នកថ្មីចេះតែឡើងទៅ អាចាស់ថយ ហើយអាថ្មីឡើងទៅ ។

ដានីៈ ចេះតែឡើងបន្តទៅ?

រឿនៈ បាទ! ដូចឆ្នាំ៧៨ហ្នឹង ខ្ញុំបានកាន់ជាអនុសេនាធំមកពីមេៗខ្ញុំគេដកទៅខាងព្រំដែនខាងកើតទៅស្វាយរៀង ។

ដានីៈ ដល់ពេល៧៨ឡើងជាអនុសេនាធំ?

រឿនៈ បាទ!

ដានីៈ ប៉ុន្តែពូនៅកោះខ្សែងដដែល?

រឿនៈ បាទ! នៅកោះខ្សែងដដែល ។

ដានីៈ អត់មានទៅណាទេ តាំងពីរហូតមក?

រឿនៈ នៅហ្នឹងរហូត ។

ដានីៈ ទាល់តែរត់យួនហ្នឹងហ្មង?

រឿនៈ បាទ!

ដានីៈ ចុះកាល៧៨ហ្នឹងយ៉ាងម៉េចដែរសភាពការណ៍ ពេលនៅតាមព្រំដែនមានការវ៉ៃនៅតាមព្រំដែន ចុះនៅខាងពូអីមានអត់?

រឿនៈ ខាងហ្នឹងអត់មានវ៉ៃទេ ។

ដានីៈ អត់មានវ៉ៃទេ?

រឿនៈ អត់ តែបើវ៉ៃគឺវ៉ៃខាងនេះ តែខ្ញុំអត់មានមកទេ ។

ដានីៈ ខាងណា?

រឿនៈ វ៉ៃជាមួយថៃ មុំយើងក្នុងយៃអីហ្នឹង អាហ្នឹងមានវ៉ៃ តែបើខាងនោះអត់មានទេ ។

ដានីៈ អត់មានវ៉ៃអីទេ?

រឿនៈ អត់ទេ រហូតដល់ឆ្នាំ៧៩ចូលធំហ្មង ។

ដានីៈ ដល់ពេល៧៩ហ្នឹងម៉េចទៅ?

រឿនៈ ៧៩និយាយទៅគឺទៅពីហ្នឹងវិញ ទៅពីភ្នំពេញហ្នឹងទៅកំពតវិញ អាហ្នឹងអត់មានទេ វ៉ៃពីហ្នឹងទៅវិញ ។

ដានីៈ ចុះពូ នៅខាងភូមិភាគបច្ចឹមហ្នឹងមានប៉ុន្មានតំបន់?

រឿនៈ កាលហ្នឹងវាមានកោះកុង មានកំពង់ស្ពឺ ហើយកំពង់ឆ្នាំង ។

ដានីៈ គណៈតំបន់ពីណាគេ?

រឿនៈ គណៈភូមិភាគ?

ដានីៈ បាទ! គណៈភូមិភាគ ។

រឿនៈ	គណៈភូមិភាគគេកាលហ្នឹងឈ្មោះ តាចាន់ស៊ី គាត់ស្លាប់តាំងពីឆ្នាំប៉ុន្មានទេ តាំងពី៧០ប៉ុន្មានទេ ភ្លេចបាត់ហើយ ។

ដានីៈ	មានពីណាទៀតក្រៅពី តាស៊ី?

រឿនៈ	មិនដឹងអ្នកណាទេ ព្រោះខ្ញុំកាលហ្នឹងខ្ញុំអត់សូវស្គាល់ ហើយអត់សូវច្បាស់ផង ។

ដានីៈ	ពូអត់សូវដឹងទេ?

រឿនៈ	ខ្ញុំដឹងតែដំបូងភូមិភាគមាន តាម៉ុក គាត់ទទួលរួមទាំងអស់ តាំងពីភូមិភាគនារតីមក តែដល់ក្រោយមកយើងចប់សង្គ្រាមហើយ មានតាអីទេ ឈ្មោះ តាស៊ី ដែរតែមិនមែន ចាន់ស៊ីទេ តែអាហ្នឹងគាត់ខាងភូមិភាគ ហើយរងពីហ្នឹងមកមានពេទ្យ សឿង ហ្នឹងឯង ។ តាសឿងគាត់ទទួលកងពលផង ហើយជាប់ដើងភូមិភាគហ្នឹងឯង ។

ដានីៈ	ចុះដែលពូឈ្មោះ តាប៉ាល់ ទេ?

រឿនៈ	តាប៉ាល់ ពូឈ្មោះតែខ្ញុំអត់ដែលឃើញគាត់ផង តាប៉ាល់ និយាយទៅគាត់រស់នៅជួរម៉ុំអស់ហ្នឹង គាត់រត់មកច្រកហ្នឹង តែគាត់ចាស់ហើយខ្ញុំអត់ដែលបានឃើញមុខគាត់ទេ តែឈ្មោះខ្ញុំដែលឮ ។

ដានីៈ	ចុះពូ ពេល៧៩ពេលដែលយួនចូលមក ពូអត់មានបានវៃបានវៃបានអីទេ?

រឿនៈ	៧៩ហ្នឹងខ្ញុំអត់ដែលបានចុះប្រឡូកវៃគ្នាតាមព្រំដែនអត់ទេ ដល់ពេលគេចូលមកដល់ព្រៃនុបបានខ្ញុំបានវៃ វៃរហូត ។

ដានីៈ	រត់ម៉េចទៅពេលដែលយួនចូលមក?

រឿនៈ	អាហ្នឹងដូចថាយើងស្ទាក់វៃ ហើយគេបុកមកអញ្ចឹងយើងចាញ់គេ ដកមួយដំណាក់ទៅត្រៀមមួយដំណាក់ទៀតអញ្ចឹងទៅ ដល់ពេលវៃមិនឈ្នះគេថយៗមកទៀត ថយៗរហូតមកដល់ព្រំដែនមក ខ្ញុំមកច្រកហ្នឹងគាត់ភ្នំហ្នឹងរហូត ខ្ញុំរត់ទៅដល់កោះកុងក្នុងយៃ កាលហ្នឹងមកឆ្លាយថ្មបាំងមកអញ្ចឹងមក ឆ្លាយមកដងទង់ ហើយធ្លាក់មកតាមព្រំដែនមកអញ្ចឹងរហូត ។

ដានីៈ	ពូនៅកងពលណាវិញទៅ?

រឿនៈ	កាលហ្នឹងបែកបាក់ពីកងពលអស់ហើយ លែងមានកងពលហើយ ដល់ពេលលែងមានកងពលហើយ វាបែកបាក់គ្នាអាតាត់អាតាយអស់ហើយ ដល់ពេលហើយខ្ញុំមកនៅតាមព្រំដែនហ្នឹងរហូត ហើយទៅនៅតាមខ្សែម នៅខ្សែមហ្នឹងរៀបចំអង្គភាពដូចថាគ្រាន់តែប្រមូលៗគ្នា មិនទាន់រៀបចំជាអង្គភាពណាធំទេ ប៉ុន្តែប្រមូលៗមនុស្សអញ្ចឹងទៅ តែអត់ទាន់មានជាអង្គភាពទេ ដល់ពេលយើងចូលឆ្នាំ៨០ តាម៉ុក គាត់កាលហ្នឹងកម្លាំងនៅខាងភ្នំដងរែកវាអត់មាន អញ្ចឹងដកពួកខ្ញុំហ្នឹងទៅខាងភ្នំដងរែក ។

ដានី៖ កាលហ្នឹងនៅជាមួយពីណាគេ?

វឿន៖ និយាយទៅកាលហ្នឹងវានៅជាប់ កាលហ្នឹង តាម៉ុក គាត់គ្រប់គ្រង តែនៅជាវរៈសេនាធំទេ អត់មានកងពលទេ ។ ខ្ញុំទៅនៅតាមព្រំដែនលាវហ្នឹងម៉ាដូរភ្នំដងរែកមកទល់លង្វែក នៅតាម ហ្នឹង នៅហ្នឹងគ្រាន់តែដូចថាយកកម្លាំងទៅ ទៅធ្វើកន្លែង ដាក់ជាឃ្លាំងអង្ករឃ្លាំងអីអញ្ចឹង ទៅ ។

ដានី៖ អញ្ចឹងពូនៅជាមួយ តាម៉ុក រហូត?

វឿន៖ ខ្ញុំនៅ និយាយទៅខាងហ្នឹងនៅខាងអន្លុងវែង តាម៉ុក គាត់កាន់មួយផ្នែកខាងហ្នឹងទាំងអស់ ដូចថាខាងនេះអញ្ចឹងមាន តានួន ជា មានតាពត អញ្ចឹងទៅ ហើយខាងប៉ៃលិនមានតា អៀង សារី ហើយទៅខាងនោះមាន តាម៉ុក ចែកគ្នានៅអញ្ចឹងណា៎ ។

ដានី៖ ហើយពូនៅជាមួយគាត់ដល់ឆ្នាំណាទៅ?

វឿន៖ ខ្ញុំមិនបាននៅជាប់ជាមួយគាត់ជិតស្និទ្ធទេ តែគ្រាន់ថាកាលហ្នឹងគាត់នៅគ្រប់គ្រងនៅកន្លែង ហ្នឹង តែគ្រាន់ថាតាំងពីយើងឆ្នាំ៨០ យើងទៅនៅខាងហ្នឹង ។

ដានី៖ ហើយម៉េចទៀតទៅ?

វឿន៖ កាលហ្នឹងនៅពីឆ្នាំ៨០មក ធ្វើការរហូតដល់ឆ្នាំ៨២ អាហ្នឹងខ្ញុំចុះមកធ្វើការចលនាតាមភូមិ វិញម្តុំយើងខាងខេត្តព្រះវិហារហ្នឹង ម៉ាដូរស្រុកសង្គមថ្មី ម៉ាដូរខាងស្វាយលើ ហើយរហូត ដល់យើងឆ្នាំ៨៤ ឆ្នាំ៨៤ហ្នឹងគេដកខ្ញុំមកនៅតាមដងទន្លេសាបវិញ នៅចាប់តាមដងទន្លេ សាបហ្នឹង តាមដងស្ទឹងសែនមកកំពង់ឆ្នាំងហ្នឹង ។

ដានី៖ មកនៅខាងកំពង់ឆ្នាំងវិញ?

វឿន៖ បាទ! តែនៅខាងនោះ ។

ដានី៖ មកនៅជាមួយពីណាគេ?

វឿន៖ កាលហ្នឹងកងពលខ្ញុំឈ្មោះ ប៉ាល ហើយអ៊ំសេង យើងនេះ ពូថន, ហើយអ៊ំផល អាហ្នឹង គាត់គណៈកងពល ហើយស៊ូ ក៏វរៈសេនាធំដែរ ។

ដានី៖ ផល ហ្នឹងប្រពន្ធគាត់មែន ដើរមេញហ្នឹង?

វឿន៖ បាទ! ប្រពន្ធគាត់ អញ្ចឹងនៅតាមដងទន្លេសាបរហូតដល់ឆ្នាំ៨៨ អង្គភាពខ្ញុំគេដកពាក់ កណ្តាលមកខាងនេះ មកធ្វើការនៅខេត្តកំពង់ឆ្នាំងយើងហ្នឹង គេដកមក មកកាត់ទន្លេសាប ហ្នឹងមក មកធ្វើនៅខេត្តកំពង់ឆ្នាំងវិញ ។ អញ្ចឹងវាឆ្នាំ៨៨ខ្ញុំបានមកដាន់ដីទន្លេសាប ។

ដានី៖ ចុះកែវ ពន់អីគាត់ទៅខាងហ្នឹងដែរ?

រឿនៈ បាទ! កែវ ពង់ គាត់នៅហ្នឹង តែគាត់នៅយូហើយ ប៉ុននៅចាប់ពីព្រំដែនមុនខ្ញុំតាំងពីឆ្នាំ៧៩ មកគាត់នៅហ្នឹង ។

ដានីៈ ប៉ុន្តែអត់នៅជាមួយក្រុមរបស់ពូទេ?

រឿនៈ អត់ទេ នៅអគ្គភាពផ្សេងៗគ្នា ។ តែអ៊ំផល ហើយនឹងអ៊ំសេង នេះ ហើយនឹង ឆន រាល់ថ្ងៃនេះចាប់ពីកំពង់ឆ្នាំងមកខាងជើង មកទល់គ្នាគេហៅស្រុកទឹកកុះ កែវ ពង់ ចាប់ពីផ្លូវមកអមលាំងអីហ្នឹងទៅត្បូង អាហ្នឹងមួយប៉ែកគាត់ ហើយទៅខាងកំពង់ស្ពឺម៉ាចំហៀងខាងត្បូងទៀតអាហ្នឹង អ៊ំសាន ហ្នឹងឯង កាលហ្នឹងគាត់ប្រធានកងពល ។

ដានីៈ គាត់ប្រធានកងពល?

រឿនៈ បាទ! អ៊ំសាន ហ្នឹងប្រធានកងពល ។

ដានីៈ ចុះពូនៅហ្នឹងរហូតដល់ពេលណាទៅ បានពូត្រលប់មកវិញ?

រឿនៈ ខ្ញុំនៅកំពង់ឆ្នាំងហ្នឹងឆ្លងមកឆ្នាំ៨៨ ប៉ុន្តែដល់ស្នាក់ការដែលធំប្រពន្ធកូនខ្ញុំនៅហ្នឹង នៅខាងអូរសរិលហ្នឹងឯង ។

ដានីៈ នៅអូរសរិលហ្នឹង?

រឿនៈ បាទ!

ដានីៈ ខាងសំឡូតវិញ?

រឿនៈ ខាងសំឡូតមកវិញ ។

ដានីៈ ចុះពូរៀបការឆ្នាំណា?

រឿនៈ ខ្ញុំតាំងពីឆ្នាំ៨១ ។

ដានីៈ រៀបការតាំងពីឆ្នាំ៨១?

រឿនៈ បាទ!

ដានីៈ ចុះមីងគាត់អ្នកស្រុកណាដែរ?

រឿនៈ ម៉ែវាអ្នកកំពត ។

ដានីៈ ពូមកជួបគ្នានៅណាទៅ?

រឿនៈ ជួបគ្នានៅភ្នំដងរែកហ្នឹង នៅអន្លង់វែងហ្នឹង ។

ដានីៈ យ៉ាងម៉េចកាលហ្នឹង ពូជួបគ្នា ម៉េចបានជាស្គាល់គ្នា ហើយរៀបការជាមួយគ្នា?

រឿនៈ កាលហ្នឹងនិយាយទៅសុទ្ធតែអ្នករត់ចូលព្រៃដូចគ្នា ដល់ពេលអញ្ចឹងទៅគ្រួសារខ្ញុំគាត់នៅខាងក្រុមមន្ទីរ មន្ទីរវរៈអញ្ចឹងទៅ ហើយដឹកជញ្ជូនអញ្ចឹងទៅ ហើយខ្ញុំនៅតាមអគ្គភាពអញ្ចឹងទៅ អញ្ចឹងវាដូចថាក្នុងមន្ទីរហ្នឹងក៏ជាអគ្គភាពរបស់ខ្ញុំដែរ អញ្ចឹងមេគេគិតគូរឲ្យខ្ញុំទៅ ។

ដានី៖ តែពូបានឃើញគាត់ដែរ?

រឿន៖ អត់បានឃើញយូទេ បើឃើញគឺឃើញតែពេលខ្លីទេ។

ដានី៖ ស្រុកកំណើតគាត់នៅកំពតហ្នឹងនៅណាទៅ?

រឿន៖ នៅឈូក។

ដានី៖ ចុះពូមកនៅនេះឆ្នាំណា?

រឿន៖ មកនៅដីហ្នឹង បើនិយាយទៅមកនៅតាំងពីឆ្នាំ៩៤-៩៥។

ដានី៖ ៩៤-៩៥?

រឿន៖ បាទ! តាំងពីគេបង្កើតជាភូមិហ្នុង ខ្ញុំមកនៅនឹងបឹងឆ្នាំ៩៥អត់មានរត់ទៅណាទេ កាលពីដើមនៅគ្មានភូមិគ្មានស្រុកទេ តាមហ្នឹងព្រៃរត់អត់រួច ហើយសុទ្ធតែព្រៃខ្លាព្រៃដីរទៀតកាលហ្នឹង។

ដានី៖ ហើយម៉េចបានជាផ្លាស់ពីហ្នឹងមកនៅនេះ?

រឿន៖ កាលហ្នឹងបើនិយាយទៅដូចថា ពីឆ្នាំ៩៣ហ្នឹងយើងមិនត្រូវរូវគ្នា អញ្ចឹងគេបំបែកប្រជាជនឲ្យមកនៅតាមព្រំដែន ម៉ាជំនួនទៅនៅគេហៅភូមិថ្មជា អញ្ចឹងគេរៀបជាភូមិនៅតាមព្រំដែនដើម្បីការពារព្រំដែន ហើយកន្លែងហ្នឹងបើនិយាយទៅខ្ញុំមិនសូវស៊ីចផ្សុក់អីទេ ដូចថាគេប្រុងបង្កើតខេត្ត អញ្ចឹងគេយកប្រជាជនមកដាក់ការពារជាខ្ទង់តាមហ្នឹងហ្នុង។ ខ្ញុំនៅតាំងពីឆ្នាំ៩៥ហ្នឹងមក ហើយផ្លូវនេះក៏អត់មានដែរកាលហ្នឹង បើមានក៏អត់មានអ្នកណាហ៊ានដើរដែរកាលហ្នឹង។

ដានី៖ ថ្មី?

រឿន៖ មីន មីនខ្លាំងណាស់ អត់មានអ្នកណាហ៊ានដើរទេ ផ្លូវចាស់ គេហៅផ្លូវ៥៦។

ដានី៖ មីនហ្នឹងខាងណាអ្នកដាក់?

រឿន៖ និយាយមីនខាង...។

ដានី៖ មីនខាងយើងអ្នកដាក់ឬក៏ខាងវៀតណាម?

រឿន៖ ខាងវៀតណាម ខាងរដ្ឋកម្ពុជា។

ដានី៖ ចុះខាងខ្មែរក្រហមនៅខាងណា?

រឿន៖ និយាយខាងៗទាំងអស់នៅជុំសុទ្ធតែខ្មែរក្រហម តែតាមផ្លូវអត់មានទេ។

ដានី៖ ដោះអស់ឆ្នាំណា មីន?

រឿន៖ ឆ្នាំ២០០១ បើនិយាយទៅផ្លូវនេះឆ្នាំ២០០១ដោះអស់ ស៊ីម៉ាក់ដែលមកធ្វើផ្លូវហ្នឹង ធ្វើបណ្ដើរដោះបណ្ដើរ។

ដានី: ពូបានទៅលេងផ្ទះនៅឆ្នាំណា ដូចថាយើងបែកពីផ្ទះតាំងពី៧២មក ហើយឆ្នាំណាបានត្រលប់ទៅលេងផ្ទះ ទៅលេងស្រុកកំណើត?

រឿន: ទៅលេងទាល់តែត្រូវរូវគ្នា ចប់ផ្តាច់ខ្លួនហ្នឹងបានទៅលេង ។

ដានី: ឆ្នាំណា?

រឿន: អាហ្នឹងយើងចូល៩៧-៩៨ហើយបានទៅលេង ។

ដានី: ទៅខាងកំពង់ឆ្នាំង ខាងស្រុកកំណើតរបស់ពូ?

រឿន: បាទ! ខាងហ្នឹង ហើយបើខាងកំពតទើបតែទៅឆ្នាំប៉ុន្មានទេ ២០០០ប៉ុន្មានទេកាលហ្នឹងមានផ្លូវ កាលហ្នឹងបើនិយាយទៅអត់មានផ្លូវទៅពោធិ៍សាត់ទេ មានតែផ្លូវព្រៃដើរទេ ។

ដានី: ពីហ្នឹងទៅពោធិ៍សាត់អត់មានផ្លូវទេ?

រឿន: អត់មានទេ បើទៅខែវស្សាមួយអាទិត្យបានមកដល់នេះវិញ បើឡានជាប់ ហើយផ្លូវនេះអត់មាន អញ្ចឹងទៅអាផ្លូវព្រៃនោះខែវស្សាទៅអត់បាន បើខែប្រាំងគ្រាន់ធូរបន្តិច តែខែប្រាំងកាលហ្នឹងចង់ទៅឡើងទៅសំឡូតវិញ ។

ដានី: ទៅខាងសំឡូតវិញ?

រឿន: បាទ! ទៅកាត់ភ្នំនេះ ទៅអញ្ចឹងទៅ ទៅខាងអូរសិរិលហ្នឹងឡើងទៅខាងហ្នឹងវិញ ។

ដានី: ចុះម៉េចដែរពេលដែលពូទៅលេងផ្ទះលើកទី១ កន្លែងអីយ៉ាងម៉េចបន្ទាប់ពីយើងបែកពីផ្ទះយូដែរតាំងពី៧២ដល់៩០ជាងបានមកវិញ ខុសប្លែកម៉េចដែរ?

រឿន: និយាយក្លេចទាំងអស់ហ្នឹង ដីដែលធ្លាប់ស្គាល់ដូចថាមិនមែនស្រុកខ្លួនឯង ព្រោះវាយូពេកទៅដូចថាដីវាវាលអញ្ចឹងទៅ អស់ព្រៃឈើធំៗទៅវាប្លែកអញ្ចឹងដែរហ្នឹង ។

ដានី: វាវាលមែន?

រឿន: បាទ! វាល ។

ដានី: ផ្ទះអីចំណាំដែរ កាលទៅដល់ដំបូង?

រឿន: អត់ទេ ពេលទៅភ្លេចអស់ ដីស្រែកន្លែងណាៗភ្លេចអស់ ។

ដានី: ហើយទៅផ្ទះធ្វើយ៉ាងម៉េចទៅ សួរគេឬក៏ពូទៅរកឃើញខ្លួនឯង?

រឿន: ទៅដល់ហ្នឹងដូចថា ប្រជាជនគេទៅនៅតាមផ្ទះអញ្ចឹងទៅ ដូចអត់មានភ្លេចទេ ផ្ទះវាមិនវង្វេងទេ គ្រាន់តែព្រៃខាងៗហ្នឹងវាភ្លេច តែបើតួផ្ទះវាមិនភ្លេចទេ អត់អីទេកាលហ្នឹង ។

ដានី: ចុះពូទៅលេងផ្ទះបានប៉ុន្មានថ្ងៃដែរ?

រឿន: កាលហ្នឹងទៅបានមួយអាទិត្យ កាលហ្នឹងទៅបានស្រួលដែរ ព្រោះទើបតែផ្តាច់ខ្លួនថ្មីៗ ។

ដានី: ចុះក្រោយមកមានដែលបានទៅលេងទៀតទេ?

រឿនៈ ទៅរាល់ឆ្នាំ ខ្ញុំមួយឆ្នាំទៅ២-៣ដង ឥលូវវាស្រួលដែរ ហើយម្ដាយខ្ញុំចាស់ គាត់អាយុឡើង ៩០ហើយហ្នឹង តែគាត់មិនទាន់ស្លាប់ផង ។

ដានីៈ ចុះកាលទៅលើកទី១ ឪពុកពូគាត់នៅទេ?

រឿនៈ ឪពុកខ្ញុំគាត់ស្លាប់តាំងពីខ្ញុំនៅតូច នៅតែម្ដាយទេ ហើយម្ដាយឥលូវគាត់ជរាហើយ ។

ដានីៈ ហើយចុះបងប្អូនពូបង្កើតគាត់នៅទេ?

រឿនៈ បងប្អូនខ្ញុំនៅស្រុកទាំងអស់ ។

ដានីៈ នៅស្រុកទាំងអស់?

រឿនៈ បាទ! តែស្លាប់អស់២នាក់ ស្លាប់កាលជំនាន់សង្គ្រាម ប្អូនបងអីនៅហ្នឹងទាំងអស់ បែកតែខ្ញុំ មួយមកនៅស្រុកគេនេះ ។

ដានីៈ ចុះពូមកដល់សព្វថ្ងៃនេះ ពូមានដែលព្រួតត៌មានទាក់ទងនឹងតុលាការគេបង្កើតជំនុំជម្រះទោស មេដឹកនាំ ដូចជាពួកខ្មែរក្រហមពូមានដែលឮទេ?

រឿនៈ ដែលឮតើ ឮតាមប៉ុស្ដិ៍វិទ្យុអីហ្នឹង ។

ដានីៈ ពូយល់ឃើញយ៉ាងម៉េចដែរ កាលដែលឮអញ្ចឹង ដូចថាយើងធ្លាប់បានធ្វើការហើយរួមរស់ នៅជាមួយពួកគាត់អញ្ចឹង បើតាមការយល់ដឹងការយល់ឃើញរបស់ពូ តើពូយល់ឃើញ យ៉ាងម៉េចដែរ?

រឿនៈ រឿងទាំងអស់ខ្ញុំដូចថា និយាយទោសម្រាប់ខ្ញុំដូចថាមិនដឹងរឿងអាក្រក់ដល់ថ្នាក់ហ្នឹង និយាយទៅកាលហ្នឹងពេលប្រជុំរៀនសូត្រហ្នឹងមេៗគាត់ហៅធ្វើការរហូត ប្រជុំប្រចាំឆ្នាំ មួយឆ្នាំអញ្ចឹងប្រជុំមួយដងទៅ ហៅរៀនសូត្រអញ្ចឹងទៅ ដឹងតែរឿងល្អៗដល់ពេលរឿង អាក្រក់អត់ដឹង អត់ដឹងផ្ទៃក្នុងគេ ។

ដានីៈ តើពូយល់ថាត្រឹមឬក៏មិនត្រឹមត្រូវ ដែលរាជរដ្ឋាភិបាលនឹងអង្គការសហប្រជាជាតិរួមគ្នា បង្កើតអញ្ចឹង?

រឿនៈ ដល់ពេលអញ្ចឹងខ្ញុំពិបាកនិយាយដែរ ពួឯងសួរខ្ញុំអញ្ចឹង ខ្ញុំមិនដឹងនិយាយថាម៉េច និយាយ ទៅវាពិបាកថាណាស់ពូ ពិបាកថាត្រង់ថាអ្វីក៏ដោយ តែបើសិនណាជាអ្នកខុសក៏ដោយឬក៏ អ្នកត្រូវ ដូចខ្ញុំហើយនឹងពូអញ្ចឹង ដូចថាពូអ្នកត្រូវចុះហើយខ្ញុំខុស តែបើសិនណាជាខ្ញុំអ្នក ខុសឈ្នះអ្នកត្រូវចាញ់ អាហ្នឹងអ្នកខុសក៏វាត្រូវហើយ ហើយអ្នកដែលខុសគឺវាត្រូវវិញ ហើយ ខ្ញុំវាពិបាកវែកញែកណាស់ អាហ្នឹងស្រេចតែយើងយល់ខ្លួនឯងទៅ តែបើសិនណា ជារឿងហ្នឹងវាដូចជាថាមែន អាហ្នឹងដូចថាថ្នាក់មេដូចគាត់ធំៗអញ្ចឹង គួណាតែគាត់គៀសខ្លួន ទៅនៅឲ្យផុត នៅប្រទេសណាឲ្យវាផុតបាត់មុខបាត់មាត់អាហ្នឹងបានថា តែអ្នកខុសហ្នឹងដូចថា

គាត់រស់នៅស៊ីអត់ស៊ីឃ្លាននៅក្នុងព្រៃអញ្ចឹងទៅរហូតអញ្ចឹងទៅ អាហ្នឹងខ្ញុំពិបាកវែកញែកណាស់ ពូពិចារណាមើល ។

ដានីៈ អញ្ចឹងពូ ខ្ញុំដូចជាអស់សំនួរអីត្រូវសួរពូទៀតហើយ តើពូមានសំនួរអីទេ?

រឿនៈ មិនដឹងមានអីទៀតទេ តែគ្រាន់តែរាល់ថ្ងៃដូចថានៅក្នុងស្រុកភូមិយើងនេះពីមុនមកដូចខ្ញុំប្រាប់ពូអញ្ចឹង ថាកន្លែងនេះពីដើមគ្មានប្រជាជននៅកន្លែងនេះទេ អញ្ចឹងកន្លែងនេះមានតែព្រៃខ្លាព្រៃដំរីទេ ទើបតែពួកខ្ញុំនេះឆ្នាំ៩៥មករស់នៅកន្លែងហ្នឹង អញ្ចឹងរស់នៅដើម្បីចង់បានទឹក ចង់បានដី រស់នៅនិយាយទៅឲ្យប្រកបការងារឲ្យគ្រាន់ថាមានបាននឹងគេខ្លះ តែបើយើងទៅស្រុកក៏មិនដឹងពឹងអី ដីតាំងពីជំនាន់ចាស់បុរាណមក អញ្ចឹងកូនចៅក៏រីកធំទៅ ហើយដីកាន់តែរួញ ម្ល៉ោះហើយនាំគ្នានៅកន្លែងហ្នឹងទៅ វាមានទឹកមានដីដូចថាវាទូលាយ អញ្ចឹងយើងរស់នៅតាំងពីឆ្នាំ៩៥ហ្នឹងមក តាំងពីអត់ផ្លូវរហូតដល់មានផ្លូវ មានដីគ្រប់គ្រាន់ តែមកដល់ឥលូវហ្នឹងវាអស់ទៅវិញ អញ្ចឹងមិនដឹងគិតរបៀបម៉េចទេ ដូចថាក្រុមហ៊ុនមកដល់ដាក់ព្រុះៗ ដីខ្ញុំពីនាក់កូនខ្ញុំអស់១០ហាត់ ។

ដានីៈ ក្រុមហ៊ុនយ៉ាងម៉េច?

រឿនៈ ក្រុមហ៊ុនវាមកឈូសឆាយអស់ ។

ដានីៈ ដីរបស់ពូយ៉ាងម៉េចបានជាគេឈូសឆាយ?

រឿនៈ ដីខ្ញុំធ្វើចំការរាល់ឆ្នាំហ្នឹង ។

ដានីៈ នៅណា?

រឿនៈ នៅក្រោយផ្ទះ ។

ដានីៈ ក្រុមហ៊ុនណា ក្រុមហ៊ុនទីភាពហ្នឹង?

រឿនៈ បាទ!

ដានីៈ គេថាម៉េច គេមកយកដីពូហ្នឹង?

រឿនៈ គេថា បើនិយាយទៅគេថាអភិវឌ្ឍលក់ឲ្យគេ ។

ដានីៈ អភិវឌ្ឍខាងណា?

រឿនៈ អភិវឌ្ឍខាងព្រៃឈើហ្នឹង ។

ដានីៈ ប៉ុន្តែដីវាលហ្នឹងគេយកធ្វើអី?

រឿនៈ ដីហ្នឹងគេធ្វើចំការកៅស៊ូធ្វើអីហ្នឹង ។

ដានីៈ អញ្ចឹងអ្នកស្រុកអ្នកភូមិហ្នឹងបានប៉ះពាល់ ដូចថាបាត់បង់ដីទៅលើក្រុមហ៊ុនហ្នឹងច្រើនគ្រួសារដែរអត់?

រឿនៈ	បើនិយាយទៅមួយភូមិខាងកើត ហើយនឹងភូមិហ្នឹងប្រហែលជា៣០-៤០គ្រួសារដែរ តែបើភូមិខាងកើតនោះគ្នាទាំងអស់ គេហៅភូមិជានាវភូមិអីនោះ គ្នាអត់មានដីជិតផ្ទះ ដីជិតផ្ទះធ្វើអីអត់កើត អញ្ចឹងមានតែឆ្ងាយ ហើយដូចខ្ញុំ៣០០ម៉ែត្រពីផ្ទះ ។

ដានីៈ	៣០០ម៉ែត្រពីក្រោយផ្ទះគេយកដែរ?

រឿនៈ	គេយក ។

ដានីៈ	ខាងរដ្ឋអំណាច ដូចថាខាងភូមិខាងឃុំគេដោះស្រាយយ៉ាងម៉េចទៅ?

រឿនៈ	ដោះស្រាយអត់ចេញ ដល់និយាយទៅភូមិគេនិយាយថាបរិស្ថានគេលក់អស់ហើយ ។

ដានីៈ	បរិស្ថាននៅខាងណា?

រឿនៈ	បរិស្ថានយើងស្រុកវាលវែងហ្នឹង ។

ដានីៈ	បរិស្ថានស្រុកអ្នកលក់?

រឿនៈ	បាទ!

ដានីៈ	ម៉េចបានជាបរិស្ថានអ្នកលក់?

រឿនៈ	និយាយទៅ ព្រោះអីដីហ្នឹងដូចថា ដីហ្នឹងគេអត់បែកតំបន់ដាច់ អញ្ចឹងប៉ុន្មានឆ្នាំមកគេមានបែកតំបន់ដាច់ណា អញ្ចឹងដល់រួមៗអញ្ចឹងក៏វាអញ្ចឹងទៅ ។

ដានីៈ	អញ្ចឹងខ្ញុំអរគុណពូច្រើន ។